អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

*ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២*

## សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ

នាថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ ដែលជាថ្ងៃឈប់សម្រាករបស់ភាគីជាតិទាំងអស់របស់អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ Laurent Kasper Ansermet បានធ្វើសេចក្តីប្រកាសព័ត៌មានមួយ ដែលទង្វើនេះគឺជាការលួចធ្វើនៅពីក្រោយខ្នងរបស់ភាគីខាងជាតិទាំងអស់។

ដើម្បីជៀសវាងការភ័ន្តច្រឡំពីសំណាក់មតិជាតិ និងអន្តរជាតិទាក់ទងនឹងសេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងដែលធ្វើឡើងនៅថ្ងៃនេះ សហចៅក្រមស៊ើបអង្កេតជាតិសូមធ្វើការគូសបញ្ជាក់ថា ដូចបានលើកឡើងរួចមកហើយនៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Laurent Kasper-Ansermet មិនមាននីតិសម្បទានៅក្នុងការបំពេញកិច្ចនីតិវិធី ឬចំណាត់ការណាមួយទាក់ទងនឹងសំណុំរឿងឡើយ ដោយរួមទាំងការផ្សព្វផ្សាយព័ត៌មានអំពីសំណុំរឿងដែលមានចែងក្នុងវិធាន ៥៦ នៃវិធានផ្ទៃក្នុង ។ ដូច្នេះហើយបានជាសហចៅក្រមស៊ើបអង្កេតជាតិមិនអាចធ្វើការពិភាក្សាជាមួយនឹងលោក Laurent Kasper Ansermet អំពីការផ្សព្វផ្សាយព័ត៌មាន ដែលមានចែងនៅក្នុងវិធាន ៥៦ នៃវិធានផ្ទៃក្នុងនេះបានឡើយ ពីព្រោះថាចំណាត់ការនេះតម្រូវឲ្យមានការឯកភាពគ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិដែលមាននីតិសម្បទាគ្រប់គ្រាន់តាមផ្លូវច្បាប់។

ឆ្លៀតក្នុងឱកាសនេះ សហចៅក្រមស៊ើបអង្កេតជាតិសូមសម្តែងនូវការសោកស្តាយយ៉ាងខ្លាំងចំពោះរបៀបរបបធ្វើការងាររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ដែលខ្វះការយោគយល់គ្នា ខ្វះការពិចារណាអំពីគោលការណ៍ច្បាប់ និងការអនុវត្តកន្លងមករបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងបំពេញការងារដូចជាអ្នកផ្សព្វផ្សាយព័ត៌មាន ជាជាងមន្ត្រីតុលាការ ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh